00281485

E2/36/5

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 13 / 02 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

**Declassified to Public**
**06 September 2012**

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 13 / 02 / 2009
ម៉ោង (Time/Heure): 14:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

## ក្រឡាបញ្ជីអង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឈ្មោះ: លោក វម៉ាម យុន ហៅ ខាំភី

ថ្ងៃ/ខែ/ឆ្នាំកំណើត: ១៩៣៣

តំណាងដោយ: លោក គីម មេងឃី, លោកស្រី Martine JACQUIN និង លោក Philippe CANONNE

អាសយដ្ឋាន: ASF France au Cambodge, No. 71, ផ្លូវទន្លេសាប, សង្កាត់ជ្រោយចង្វា, ភ្នំពេញ

យោងសំណុំរឿងលេខ: ០០១/១៨-០៧-២០០៧-អវតក/អជសដ

**កម្មវត្ថុ: ការទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណីបណ្តោះអាសន្ន**

១. ក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូង បានទទួលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោក ហើយពាក្យសុំនេះបានដាក់បញ្ចូលក្នុងសំណុំរឿងរួចហើយ ដូចដែលបានបញ្ជាក់ខាងលើតាមបញ្ជាពីចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង ។

២. ជាវិធានការបណ្តោះអាសន្ន លោកត្រូវបានទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងដំណើរការនីតិវិធីរហូតដល់សវនាការបឋមនៅក្នុងរឿងក្តីនេះ ដែលនៅពេលនោះពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោក នឹងត្រូវលើកយកមកពិចារណាស្របតាមបញ្ញត្តិនៃវិធាន៨៣។

**ការតំណាងតាមផ្លូវច្បាប់**

៣. លើសពីនេះទៅទៀត ក្រឡាបញ្ជីក៏បានទទួលផងដែរនូវការចង្អុលបង្ហាញរបស់លោក ដែលថាលោកមេធាវី គីម មេងឃី, លោកស្រី Martine JACQUIN និង លោក Philippe CANONNE ធ្វើជាអ្នកតំណាង ដែលច្បាប់បានកំណត់ នៅក្នុងរឿងក្តីនេះ ហើយលិខិតផ្ទេរសិទ្ធិតំណាងដោយអាណត្តិពាក់ព័ន្ធក៏បានដាក់ជូនមកផងដែរ ។

ដូច្នេះ លើកលែងតែមានការសម្រេចផ្សេងពីនេះដោយអង្គជំនុំជម្រះសាលាដំបូង ឬកំណត់ដោយវិធានផ្ទៃក្នុង ការចូលរួមណាមួយជាភាគីដើមបណ្តឹងរដ្ឋប្បវេណីនឹងត្រូវធ្វើតាមរយៈមេធាវីរបស់លោក ។

**អំណាចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការប្រកាសមិនទទួលយកនូវពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី**

៤. អង្គជំនុំជម្រះសាលាដំបូងអាចធ្វើសេចក្តីសម្រេចជាផ្លូវការក្នុងការទទួលយក នូវពាក្យសុំរបស់លោក ហើយក៏អាចបដិសេធចោលផងដែរនូវពាក្យសុំនេះ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថាពាក្យសុំរបស់លោកមិនបានបំពេញតាមលក្ខណៈវិនិច្ឆ័យតាមផ្លូវច្បាប់ថាជាជនរងគ្រោះ ដូចដែលបានចែងក្នុងវិធានផ្ទៃក្នុង និងសេចក្តីណែនាំអនុវត្តស្តីអំពីការចូលរួមនៃជនរងគ្រោះ។

**ការគោរពគោលការណ៍នៃការរក្សាការសម្ងាត់**

៥. លោកត្រូវដឹងថា តាមរយៈការចូលរួមរបស់លោកស្រីជាភាគីដើមបណ្តឹងរដ្ឋប្បវេណី មេធាវីរបស់លោក និង/ឬបុគ្គលផ្សេងទៀតដែលជួយដល់លោកអាចទទួលបានព័ត៌មានសម្ងាត់ដែលមាននៅក្នុងសំណុំរឿងបាន។ មានតែចៅក្រមនៃ អ.វ.ត.ក ប៉ុណ្ណោះដែលអាចសម្រេចបានថាព័ត៌មានខាងលើជាព័ត៌មានសាធារណៈ។ លោកនិងមេធាវីទាំងអស់ត្រូវមានកាតព្វកិច្ចមិនឱ្យផ្សព្វផ្សាយនូវព័ត៌មានសម្ងាត់ទាំងនេះទេ ។

**ការជូនដំណឹងពីបញ្ជីឈ្មោះសាក្សី និងឯកសារផ្សេងៗ**

៦. ភ្ជាប់ជាមួយលិខិតនេះ មេធាវីរបស់លោកនឹងត្រូវទទួលបានការជូនដំណឹងអំពីបញ្ជីឈ្មោះសាក្សី និងអ្នកជំនាញ ដែលសហព្រះរាជអាជ្ញាមានបំណងកោះហៅឱ្យចូលរួមក្នុងពេលសវនាការ ព្រមទាំងឯកសារដែលពាក់ព័ន្ធផ្សេងៗទៀត ។ តាមបញ្ញត្តិនៃវិធាន ៨០(២) នៃវិធានផ្ទៃក្នុង រាល់ដើមបណ្តឹងរដ្ឋប្បវេណីដែលមានបំណងកោះហៅសាក្សី ឬអ្នកជំនាញណាមួយដែលមិនមានឈ្មោះក្នុងបញ្ជីដែលផ្តល់ឱ្យដោយសហព្រះរាជអាជ្ញា ត្រូវដាក់បញ្ជីឈ្មោះសាក្សីបន្ថែមក្នុងរយៈពេល ១៥ ថ្ងៃ គិតចាប់ពីថ្ងៃទទួលដំណឹងនៃបញ្ជីឈ្មោះសាក្សីរបស់សហព្រះរាជអាជ្ញានេះ ។

**ការទទួលបានព័ត៌មានបន្ថែម**

៧. ប្រសិនលោកត្រូវការការណែនាំបន្ថែម ទាក់ទងនឹងការចូលរួមក្នុងកិច្ចដំណើរការនីតិវិធី សូមអញ្ជើញទំនាក់ទំនងជាមួយអង្គភាពជនរងគ្រោះ។ វិធានផ្ទៃក្នុង និងសេចក្តីណែនាំអនុវត្តស្តីពីការចូលរួមនៃជនរងគ្រោះនៅចំពោះមុខ អ.វ.ត.ក អាចជាឯកសារសម្រាប់ពិគ្រោះយោបល់ ដែលឯកសារទាំងនេះអាចដកស្រង់ចេញពីគេហទំព័ររបស់អង្គភាពជនរងគ្រោះ(http://www.eccc.gov.kh/english/victims_unit.aspx)។

E2/36/5

០០១/១៨-០៧-២០០៧-អវតក/អជសង

ភ្នំពេញ ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០០៩

**ក្រឡាបញ្ជី**

**ឌុច ផារី** Matteo CRIPPA